**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

លេខ: ០៩៤ សស-ណា

ថ្ងៃអង្គារ ៩រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដូចខាងក្រោមៈ

១-កញ្ចប់"ក": ការផ្គត់ផ្គង់ប្រេងរំអិល និងខ្លាញ់គោ

២-កញ្ចប់"ខ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធ SCADA

៣-កញ្ចប់"គ": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធយន្តសាស្ត្រ

៤-កញ្ចប់"ឃ": ការផ្គត់ផ្គង់ថ្នាំប្រតិករគីមី ឧបករណ៍ GLASSWARE និងគ្រឿងបន្លាស់

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃព្រហស្បតិ៍ ទី១១ ខែមិថុនា ឆ្នាំ២០២៦ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់១៦:៣០នាទី) ដល់ថ្ងៃពុធ ទី១៥ ខែកក្កដា ឆ្នាំ២០២៦ ត្រឹមវេលាម៉ោង ១៤:០០នាទី។

កាលបរិច្ឆេទបង្ហាញទីតាំងគ្រឿងបន្លាស់ប្រព័ន្ធ SCADA និងគ្រឿងបន្លាស់ប្រព័ន្ធយន្តសាស្ត្រ ថ្ងៃអង្គារ ទី២៣ ខែមិថុនា ឆ្នាំ២០២៦ វេលាម៉ោង ០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធ SCADA និងគ្រឿងបន្លាស់ប្រព័ន្ធយន្តសាស្ត្រ គឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃព្រហស្បតិ៍ ទី១៦ ខែកក្កដា ឆ្នាំ២០២៦ កញ្ចប់"ក" វេលាម៉ោង ១៤:០០នាទី, កញ្ចប់"ខ" វេលាម៉ោង ១៤:១៥នាទី, កញ្ចប់"គ" វេលាម៉ោង ១៤:៣០នាទី និងកញ្ចប់"ឃ" វេលាម៉ោង ១៤:៤៥នាទី នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ដួ-ផល្លា**

ចម្លងជូនៈ
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ

អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ៣១ ៩៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

KINGDOM OF CAMBODIA

NATION RELIGION KING

PHNOM PENH

WATER SUPPLY AUTHORITY

Nº ....095 PPWSA.....

Date: ...9 - June - 2026..........

## Invitation for Bids

Phnom Penh Water Supply Authority (PPWSA) now invites sealed bids from eligible Bidders registered in the Kingdom of Cambodia for the Supply and Delivery of:

1-Package "A": Oil and Grease

2-Package "B": Spare parts of SCADA system

3-Package "C": Spare parts of Mechanical system

4-Package "D": Reagent, Glassware and Spare Parts

A complete set of bidding document is available upon payment of non-refundable fee at Procurement Unit of PPWSA with the address #45, Street 106, Sangkat Srash Chork, Khan Daun Penh, Phnom Penh, working hour from Thursday 11th June 2026 (08:00am to 16:30pm) until Wednesday 15th July 2026 at 14:00pm.

Date of location of spare parts of SCADA system and spare parts of Mechanical system Tuesday 23rd June 2026, at 9:00 AM. Failure to inspect SCADA and Mechanical parts is the responsibility of the bidder.

Completed bids must be delivered and opened to the address above at or before **14:00pm Package "A", 14:15pm Package "B", 14:30pm Package "C" and 14:45pm Package "D" on Thursday 16th July 2026.** Late bids will be rejected.

All bids must be accompanied by a bid security in an amount as stated in the bidding document.

Associated bidders are allowed to submit only one bid.

Interested eligible bidders may obtain further information from Procurement Unit of PPWSA at the address above or phone number 017 811 911.